គណិតវិទ្យាថ្ងៃនេះ

Mathtoday

សៀវភៅគណិតវិទ្យាកម្រិតវិទ្យាល័យ

លីមីតនៃអនុគមន៍

* សង្ខេបមេរៀននិងគន្លឹះដោះស្រាយសំខាន់ៗ
* លំហាត់ជ្រើសរើសអមដោយដំណោះស្រាយក្បោះក្បាយ
* លំហាត់ជ្រើសរើសសម្រាប់កិច្ចការផ្ទះ

សម្រាប់ថ្នាក់ទី១២ ថ្នាក់វិទ្យាសាស្ត្រពិតនិងថ្នាក់វិទ្យាសាស្ត្រសង្គម

អ្នករៀបរៀង លឹម ផល្គុន

2020

ស្របតាមកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំយុវជននិងកីឡា

ជំពូកទី០១

សង្ខេបមេរៀនលីមីតនៃអនុគមន៍

១-លីមីតនៃអនុគមន៍ត្រង់ចំនួនកំណត់

✧ **និយមន័យ**

អនុគមន៍ f មានលីមីត L កាលណា x ខិតជិត a បើគ្រប់ចំនួន $\varepsilon > 0$ មានចំនួន $\delta > 0$ ដែល $0 < |x-a| < \delta$ នាំឲ្យ $|f(x)-L| < \varepsilon$ ។

គេកំណត់សរសេរ $\lim_{x\to a} f(x) = L$ ។

ឧទាហរណ៍ ដោយប្រើនិយមន័យបង្ហាញថា $\lim_{x\to 2}(3x+1) = 7$?

យើងត្រូវបង្ហាញថា ចំពោះគ្រប់ចំនួន $\varepsilon > 0$ មាន $\delta > 0$ ដែល $|(3x+1)-7| < \varepsilon$ កាលណា $0 < |x-2| < \delta$ ។

គេបាន $|(3x+1)-7| < \varepsilon \Leftrightarrow |3(x-2)| < \varepsilon$ គ្រប់ $\varepsilon > 0$

សមមូល $|x-2| < \dfrac{\varepsilon}{3}$ យក $\delta = \dfrac{\varepsilon}{3}$ នោះ $|x-2| < \delta$ ។

សម្រាយនេះបញ្ជាក់ថាគ្រប់ $\varepsilon > 0$ មាន $\delta = \dfrac{\varepsilon}{2} > 0$ ដែល $|x-2| < \delta$ នាំឲ្យ $|(3x+1)-7| < \varepsilon$ ។ ដូចនេះ $\lim_{x\to 2}(3x+1) = 7$ ។

✧ **និយមន័យ**

អនុគមន៍ f ខិតទៅរក $+\infty$ ឬ $-\infty$ កាលណា x ខិតជិត a បើគ្រប់ចំនួន $M > 0$ មានចំនួន $\delta > 0$ ដែល $0 < |x-a| < \delta$ នាំឲ្យ $f(x) > M$ ឬ $f(x) < -M$ ។

គេកំណត់សរសេរ $\lim_{x\to a} f(x) = +\infty$ ឬ $\lim_{x\to a} f(x) = -\infty$ ។

ឧទាហរណ៍ គេឲ្យអនុគមន៍ f កំណត់ដោយ $f(x)=\dfrac{2x+3}{x-2}$

ចូរស្រាយតាមនិយមន័យថា $\lim\limits_{x\to 2^+} f(x)=+\infty$ ។

គេមាន $f(x)=\dfrac{2x+3}{x-2}=\dfrac{2(x-2)+7}{x-2}=2+\dfrac{7}{x-2}$ ។ យើងនឹងរកចំនួន $M>0$

ដែល $f(x)>M$ ។ ដើម្បីឲ្យ $f(x)>M$ យើងគ្រាន់តែឲ្យ $\dfrac{7}{x-2}>M$ និង $x>2$

គេទាញបាន $0<x-2<\dfrac{7}{M}$ យក $\delta=\dfrac{7}{M}>0$ នោះ $0<x-2<\delta$

សម្រាយនេះបញ្ជាក់ថាគ្រប់ចំនួន $M>0$ មាន $\delta=\dfrac{7}{M}>0$

ដែល $0<|x-2|<\delta$ នាំឲ្យ $f(x)>M$ ។ ដូចនេះ $\lim\limits_{x\to 2^+} f(x)=+\infty$ ។

២-លីមីតនៃអនុគមន៍ត្រង់អនន្ត

✧ **និយមន័យ** អនុគមន៍ f មានលីមីត L កាលណា x ខិតទៅ $+\infty$ ឬ $-\infty$

បើគ្រប់ចំនួន $\varepsilon>0$ មានចំនួន $N>0$ ដែល $x>N$ ឬ $x<-N$ នាំឲ្យ

$|f(x)-L|<\varepsilon$ ។ គេកំណត់សរសេរ $\lim\limits_{x\to+\infty} f(x)=L$ ឬ $\lim\limits_{x\to-\infty} f(x)=L$ ។

ឧទាហរណ៍ គេមានអនុគមន៍ f កំណត់ដោយ $f(x)=\dfrac{4x+1}{2x+3}$

ចូរស្រាយថា $\lim\limits_{x\to-\infty} f(x)=2$ និង $\lim\limits_{x\to+\infty} f(x)=2$ ។

គេមាន $f(x)=\dfrac{4x+1}{2x+3}=\dfrac{2(2x+3)-5}{2x+3}=2-\dfrac{5}{2x+3}$ នាំឲ្យ $|f(x)-2|=\dfrac{5}{|2x+3|}$

ចំពោះ $|f(x)-2|<\varepsilon$, $\varepsilon>0$ គេបាន $\dfrac{5}{|2x+3|}<\varepsilon$ នាំឲ្យ $|2x+3|>\dfrac{5}{\varepsilon}$

គេទាញ $\left[\begin{array}{l} 2x+3>\dfrac{5}{\varepsilon} \\ 2x+3<-\dfrac{5}{\varepsilon}\end{array}\right.$ សមមូល $\left[\begin{array}{l} x>\dfrac{5}{2\varepsilon}-\dfrac{3}{2} \\ x<-\dfrac{5}{2\varepsilon}-\dfrac{3}{2}\end{array}\right.$ ហេតុនេះចំពោះគ្រប់ $\varepsilon>0$

មាន $A=\dfrac{5}{2\varepsilon}$ ឬ $A=\dfrac{5}{2\varepsilon}+\dfrac{3}{2}$ ដែល $x>A$ ឬ $x<-A$ នាំឲ្យ $|f(x)-2|<\varepsilon$

ដូចនេះ $\lim_{x\to -\infty} f(x) = 2$ និង $\lim_{x\to +\infty} f(x) = 2$ ។

✧ **និយមន័យ** អនុគមន៍ f មានលីមីត $+\infty$ កាលណា x ខិតទៅ $+\infty$ បើគ្រប់ចំនួន $M>0$ មានចំនួន $N>0$ ដែល $x>N$ នាំឲ្យ $f(x)>M$ ។

គេកំណត់សរសេរ $\lim_{x\to+\infty} f(x) = +\infty$ ។

✧ **និយមន័យ** អនុគមន៍ f មានលីមីត $+\infty$ កាលណា x ខិតទៅ $-\infty$ បើគ្រប់ចំនួន $M>0$ មានចំនួន $N>0$ ដែល $x<-N$ នាំឲ្យ $f(x)>M$ ។

គេកំណត់សរសេរ $\lim_{x\to -\infty} f(x) = +\infty$ ។

៣-ប្រមាណវិធីលើលីមីត

បើ $\lim_{x\to a} f(x) = L$, $\lim_{x\to a} g(x) = M$ និង $\lim_{x\to a} h(x) = N$ ដែល L , M និង N ជាចំនួនពិតនោះគេបាន ៖

ក. $\lim_{x\to a}[f(x)+g(x)-h(x)] = L+M-N$

ខ. $\lim_{x\to a}[\alpha f(x)+\beta g(x)-\gamma h(x)] = \alpha L+\beta M-\gamma N$ ($\alpha,\beta,\gamma\in\mathbb{R}$)។

គ. $\lim_{x\to a}[f(x)g(x)h(x)] = L.M.N$

ឃ. $\lim_{x\to a}[\frac{f(x)}{g(x)}] = \frac{L}{M}$ ដែល $M\neq 0$

៤-លីមីតនៃអនុគមន៍អសនិទាន

រូបមន្តសំខាន់ៗគួរកត់សម្គាល់ ៖

ក. $\lim_{x\to a}\sqrt[n]{x} = \sqrt[n]{a}$

ខ. $\lim_{x\to a}\sqrt[n]{f(x)} = \sqrt[n]{\lim_{x\to a} f(x)}$

៥-លីមីតនៃអនុគមន៍បណ្ដាក់

បើ f និង g ជាអនុគមន៍ពីរដែលមានលីមីត $\lim_{x\to a} g(x) = L$ និង $\lim_{x\to L} f(x) = f(L)$

នោះ $\lim_{x\to a} f[g(x)] = f(L)$ ។

ឧទាហរណ៍ គណនាលីមីត $\lim_{x\to 2} \ln(\frac{4x+7}{x+3})$

តាង $g(x) = \frac{4x+7}{x+3}$ និង $f(x) = \ln x$ នោះ $f[g(x)] = \ln(\frac{4x+7}{x+3})$

គេមាន $\lim_{x\to 2} g(x) = \lim_{x\to 2} \frac{4x+7}{x+3} = \frac{8+7}{2+3} = 3$

ដូចនេះ $\lim_{x\to 2} f[g(x)] = \lim_{x\to 3} f(x) = f(3) = \ln 3$ ។

ឧទាហរណ៍ គណនាលីមីត $\lim_{x\to +\infty} \ln(\frac{4x+7}{x+3})$

តាង $g(x) = \frac{4x+7}{x+3}$ និង $f(x) = \ln x$ នោះ $f[g(x)] = \ln(\frac{4x+7}{x+3})$

គេមាន $\lim_{x\to +\infty} g(x) = \lim_{x\to +\infty} \frac{4x+7}{x+3} = \lim_{x\to +\infty} \frac{4+\frac{7}{x}}{1+\frac{3}{x}} = \frac{4}{1} = 4$

ដូចនេះ $\lim_{x\to +\infty} f[g(x)] = \lim_{x\to 4} f(x) = \lim_{x\to 4} \ln x = \ln 4 = 2\ln 2$ ។

៦-លីមីតតាមការប្រៀបធៀប

ក.បើ f និង g ជាអនុគមន៍ពីរហើយ A ជាចំនួនពិតមួយដែលចំពោះ $\forall x \geq A$ គេមាន

$f(x) \geq g(x)$ និង $\lim_{x\to +\infty} g(x) = +\infty$ នោះ $\lim_{x\to +\infty} f(x) = +\infty$ ។

ខ.បើ f និង g ជាអនុគមន៍ពីរហើយ A ជាចំនួនពិតមួយដែលចំពោះ $\forall x \geq A$ គេមាន

$f(x) \leq g(x)$ និង $\lim_{x\to +\infty} g(x) = -\infty$ នោះ $\lim_{x\to +\infty} f(x) = -\infty$ ។

គ.បើ f, g និង h ជាអនុគមន៍បី ហើយ A ជាចំនួនពិតមួយដែលចំពោះ $\forall x \geq A$

គេមាន $g(x) \leq f(x) \leq h(x)$ និង $\lim_{x\to +\infty} g(x) = \lim_{x\to +\infty} h(x) = \lambda$ នោះ $\lim_{x\to +\infty} f(x) = \lambda$

ឃ.បើ f និង g ជាអនុគមន៍ពីរ ហើយ A ជាចំនួនពិតមួយដែលចំពោះ $\forall x \ge A$ គេមាន $f(x) \le g(x)$ និង $\lim\limits_{x\to+\infty} f(x) = \lambda$, $\lim\limits_{x\to+\infty} g(x) = \lambda'$ នោះ $\lambda \le \lambda'$ ។ (λ និង λ' ជាចំនួនពិត) ។

៨-លីមីតនៃអនុគមន៍ត្រីកោណមាត្រ

ទ្រឹស្តីបទ បើ x ជារង្វាស់មុំ ឬ ធ្នូគិតជារ៉ាដ្យង់នោះគេបាន ៖

ក. $\lim\limits_{x\to 0}\dfrac{\sin x}{x} = 1$ ខ. $\lim\limits_{x\to 0}\dfrac{1-\cos x}{x} = 0$ គ. $\lim\limits_{x\to 0}\dfrac{\tan x}{x} = 1$

សម្រាយបញ្ជាក់ ៖



តាង φ ជាមុំគិតជារ៉ាដ្យង់ ដែល $0 < \varphi < \dfrac{\pi}{2}$ ។ តាង S_{OAT} , $S_{O\overset{\frown}{AP}}$ និង S_{OAP} រៀងគ្នាជាផ្ទៃក្រឡានៃត្រីកោណ OAT ផ្ទៃក្រឡាចំរៀកថាស $O\overset{\frown}{AP}$ និងផ្ទៃក្រឡានៃត្រីកោណ OAP ។ តាមរូបខាងលើគេមាន $S_{OAT} \ge S_{O\overset{\frown}{AP}} \ge S_{OAP}$

ដោយ $S_{OAT} = \dfrac{1}{2}\times 1 \times \tan\varphi$, $S_{O\overset{\frown}{AP}} = \dfrac{1}{2}\times 1^2 \times \varphi$ និង $S_{OAP} = \dfrac{1}{2}\sin\theta$

នោះគេបាន $\frac{1}{2}\tan\varphi \ge \frac{1}{2}\varphi \ge \frac{1}{2}\sin\varphi$ ឬ $\tan\varphi \ge \varphi \ge \sin\varphi$

ដោយ $\tan\varphi = \frac{\sin\varphi}{\cos\varphi}$ នោះ $\frac{\sin\varphi}{\cos\varphi} \ge \varphi \ge \sin\varphi$ នោះគេទាញ $\cos\varphi \le \frac{\sin\varphi}{\varphi} \le 1$ ។

បើ $-\frac{\pi}{2} < \varphi < 0$ នោះ $0 < -\varphi < \frac{\pi}{2}$ នោះវិសមភាពខាងលើអាចសរសេរទៅជា

$\cos(-\varphi) \le \frac{\sin(-\varphi)}{-\varphi} \le 1$ ឬ $\cos\varphi \le \frac{\sin\varphi}{\varphi} \le 1$

ហេតុនេះគេបាន $\cos\varphi \le \frac{\sin\varphi}{\varphi} \le 1$ ចំពោះគ្រប់ $\varphi \in (-\frac{\pi}{2}, 0) \cup (0, \frac{\pi}{2})$

ដោយ $\lim_{\varphi\to 0}\cos\varphi = 1$ នោះ $\lim_{x\to 0}\frac{\sin\varphi}{\varphi} = 1$ ។

ដោយជំនួស φ ដោ x នោះគេបាន $\lim_{x\to 0}\frac{\sin x}{x} = 1$ ពិត ។

ម្យ៉ាងទៀត $\lim_{x\to 0}\frac{1-\cos x}{x} = \lim_{x\to 0}\frac{(1-\cos x)(1+\cos x)}{x(1+\cos x)}$

$$= \lim_{x\to 0}\frac{\sin x}{x}.\frac{\sin x}{1+\cos x} = 1\times 0 = 0$$

ដូចនេះ $\lim_{x\to 0}\frac{1-\cos x}{x} = 0$ ពិត ។ តាមរូបមន្ត $\tan x = \frac{\sin x}{x}$

គេបាន $\lim_{x\to 0}\frac{\tan x}{x} = \lim_{x\to 0}\frac{\sin x}{x}.\frac{1}{\cos x} = 1\times 1 = 1$ ។ ដូចនេះ $\lim_{x\to 0}\frac{\tan x}{x} = 1$ ។

សម្គាល់ ៖

ក. $\lim_{x\to 0}\frac{x}{\sin x} = 1$ ខ. $\lim_{x\to 0}\frac{x}{\tan x} = 1$

៩-លីមីតនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល

រូបមន្តសំខាន់ៗ ៖

ក. $\lim_{x\to+\infty} e^x = +\infty$ ខ. $\lim_{x\to-\infty} e^x = 0$ គ. $\lim_{x\to+\infty}\frac{e^x}{x} = +\infty$

ឃ. $\lim_{x\to+\infty}\frac{x}{e^x} = 0$ ង. $\lim_{x\to+\infty}\frac{e^x}{x^n} = +\infty$ ច. $\lim_{x\to+\infty}\frac{x^n}{e^x} = +\infty$

១០-លីមីតនៃអនុគមន៍លោការីតនេពែ

រូបមន្តសំខាន់ៗ ៖

ក. $\lim_{x \to +\infty} \ln x = +\infty$

ខ. $\lim_{x \to 0^+} \ln x = -\infty$

គ. $\lim_{x \to +\infty} \frac{\ln x}{x} = 0$

ឃ. $\lim_{x \to 0^+} x \ln x = 0$

ង. $\lim_{x \to +\infty} \frac{\ln x}{x^n} = 0$

ច. $\lim_{x \to 0^+} x^n \ln x = 0$

www.mathtoday.wordpress.com

ជំពូកទី០២

វិធីសាស្រ្តគណនាលីមីតនៃអនុគមន៍មួយចំនួន

១.វិធីសាស្រ្តគណនាលីមីតតាមការដាក់ជាផលគុណកត្តា

ឧបមាថាគេមានលីមីត $\lim_{x\to a}\frac{f(x)}{g(x)}$ (1) ។

បើតម្លៃលេខ $g(a)=0$ និង $f(a)=0$ នោះលីមីត (1) មានរាងមិនកំនត់ $\frac{0}{0}$ ។ ក្នុងករណីនេះដើម្បីគណនាលីមីតគេត្រូវដាក់ភាគយកនិងភាគបែងជាផលគុណនៃកត្តាដោយមាន $(x-a)$ ជាកត្តារួមរួចសម្រួលកត្តារួមនេះចោលបន្ទាប់មករកលីមីតនៃប្រភាគថ្មី ។

ឧទាហរណ៍ គណនាលីមីត $\lim_{x\to -2}\frac{x^3+8+4(x+2)}{x^2-4}$

គេបាន $\lim_{x\to -2}\frac{x^3+8+4(x+2)}{x^2-4}=\lim_{x\to -2}\frac{(x+2)(x^2-2x+4)+4(x+2)}{(x-2)(x+2)}$

$$=\lim_{x\to -2}\frac{(x+2)(x^2-2x+8)}{(x-2)(x+2)}$$

$$=\lim_{x\to -2}\frac{x^2-2x+8}{x-2}=-\frac{16}{4}=-4$$

ដូចនេះ $\lim_{x\to -2}\frac{x^3+8+4(x+2)}{x^2-4}=-4$ ។

២.របៀបគណនាលីមីតអនុគមន៍អសនិទាន

ក.ករណីកន្សោមរាង $\sqrt{A}-B$

គេមាន $(\sqrt{A}-B)(\sqrt{A}+B)=A-B^2$ នោះគេបាន $\sqrt{A}-B=\frac{A-B^2}{\sqrt{A}+B}$

ឧទាហរណ៍ គណនាលីមីត $\lim_{x\to1}\frac{\sqrt{2x^2-2x+1}-x}{(x-1)^2}$?

ដំណោះស្រាយ

យើងបាន $\lim_{x\to1}\frac{\sqrt{2x^2-2x+1}-x}{(x-1)^2}=\lim_{x\to1}\frac{2x^2-2x+1-x^2}{(x-1)^2(\sqrt{2x^2-2x+1}+x)}$

$$=\lim_{x\to1}\frac{(x-1)^2}{(x-1)^2(\sqrt{2x^2-2x+1}+x)}$$

$$=\lim_{x\to1}\frac{1}{\sqrt{2x^2-2x+1}+x}=\frac{1}{1+1}=\frac{1}{2}$$

ដូចនេះ $\lim_{x\to1}\frac{\sqrt{2x^2-2x+1}-x}{(x-1)^2}=\frac{1}{2}$ ។

ខ.ករណីកន្សោមរាង $A-\sqrt{B}$

គេមាន $(A-\sqrt{B})(A+\sqrt{B})=A^2-B$ នោះគេបាន $A-\sqrt{B}=\frac{A^2-B}{A+\sqrt{B}}$

ឧទាហរណ៍ គណនាលីមីត $\lim_{x\to2}\frac{2x+1-\sqrt{3x^2+8x-3}}{(x-2)^2}$ ។

ដំណោះស្រាយ

យើងបាន $\lim_{x\to2}\frac{2x+1-\sqrt{3x^2+8x-3}}{(x-2)^2}=\lim_{x\to2}\frac{(2x+1)^2-(3x^2+8x-3)}{(x-2)^2(2x+1+\sqrt{3x^2+8x-3})}$

$$=\lim_{x\to2}\frac{4x^2+4x+1-3x^2-8x+3}{(x-2)^2(2x+1+\sqrt{3x^2+8x+3})}$$

$$=\lim_{x\to2}\frac{(x-2)^2}{(x-2)^2(2x+1+\sqrt{3x^2+8x+3})}$$

$$=\lim_{x\to2}\frac{1}{2x+1+\sqrt{3x^2+8x-3}}=\frac{1}{10}$$

គ.ករណីកន្សោមរាង $\sqrt{A}-\sqrt{B}$

គេមាន $(\sqrt{A}-\sqrt{B})(\sqrt{A}+\sqrt{B})=A-B$ នោះគេបាន $\sqrt{A}-\sqrt{B}=\dfrac{A-B}{\sqrt{A}+\sqrt{B}}$

ឧទាហរណ៍ គណនាលីមីត $\lim\limits_{x\to 2}\dfrac{\sqrt{x^3+1}-\sqrt{6x^2-12x+9}}{(x-2)^3}$ ។

ដំណោះស្រាយ

យើងបាន $\lim\limits_{x\to 2}\dfrac{\sqrt{x^3+1}-\sqrt{6x^2-12x+9}}{(x-2)^3}$

$$=\lim_{x\to 2}\frac{(x^3+1)-(6x^2-2x+9)}{(x-2)^3(\sqrt{x^3+1}+\sqrt{6x^2-12x+9})}$$

$$=\lim_{x\to 2}\frac{(x-2)^3}{(x-2)^3(\sqrt{x^3+1}+\sqrt{6x^2-12x+9})}$$

$$=\lim_{x\to 2}\frac{1}{(\sqrt{x^3+1}+\sqrt{6x^2-12x+9})}=\frac{1}{6}$$

ដូចនេះ $\lim\limits_{x\to 2}\dfrac{\sqrt{x^3+1}-\sqrt{6x^2-12x+9}}{(x-2)^3}=\dfrac{1}{6}$ ។

ឃ.ករណីកន្សោមរាង $\sqrt[3]{A}-B$

គេមាន $(\sqrt[3]{A}-B)(\sqrt[3]{A^2}+B\sqrt[3]{A}+B^2)=A-B^3$

នោះគេបាន $\sqrt[3]{A}-B=\dfrac{A-B^3}{\sqrt[3]{A^2}+B\sqrt[3]{A}+B^2}$ ។

ឧទាហរណ៍ គណនាលីមីត $\lim\limits_{x\to 1}\dfrac{\sqrt[3]{2x^3+6x}-x-1}{(x-1)^3}$?

ដំណោះស្រាយ

យើងបាន $\lim\limits_{x\to 1}\dfrac{\sqrt[3]{2x^3+6x}-x-1}{(x-1)^3}$

$$=\lim_{x\to1}\frac{(2x^3+6x)-(x+1)^3}{(x-1)^3\left[\sqrt[3]{(2x^3+6x)^2}+(x+1)\sqrt[3]{2x^3+6x}+(x+1)^2\right]}$$

$$=\lim_{x\to1}\frac{2x^3+6x-x^3-3x^2-3x-1}{(x-1)^3\left[\sqrt[3]{(2x^3+6x)^2}+(x+1)\sqrt[3]{2x^3+6x}+(x+1)^2\right]}$$

$$=\lim_{x\to1}\frac{(x-1)^3}{(x-1)^3\left[\sqrt[3]{(2x^3+6x)^2}+(x+1)\sqrt[3]{2x^3+6x}+(x+1)^2\right]}$$

$$=\lim_{x\to1}\frac{1}{\sqrt[3]{(2x^3+6x)^2}+(x+1)\sqrt[3]{2x^3+6x}+(x+1)^2}=\frac{1}{12}$$

ង.ករណីកន្សោមរាង $A-\sqrt[3]{B}$

គេមាន $(A-\sqrt[3]{B})(A^2+A\sqrt[3]{B}+\sqrt[3]{B^2})=A^3-B$

នោះគេបាន $A-\sqrt[3]{B}=\dfrac{A^3-B}{A^2+A\sqrt[3]{B}+\sqrt[3]{B^2}}$ ។

ឧទាហរណ៍ គណនាលីមីត $\lim_{x\to2}\dfrac{x-1-\sqrt[3]{4x^2-12x+7}}{(x-2)^3}$?

ដំណោះស្រាយ

តាង $L=\lim_{x\to2}\dfrac{x-1-\sqrt[3]{4x^2-12x+7}}{(x-2)^3}$

$$=\lim_{x\to2}\frac{(x-1)^3-(4x^2-12x+7)}{(x-2)^3\left[(x-1)^2+(x-1)\sqrt[3]{4x^2-12x+7}+\sqrt[3]{(4x^2-12x+7)^2}\right]}$$

$$=\lim_{x\to2}\frac{(x-2)^3}{(x-2)^3\left[(x-1)^2+(x-1)\sqrt[3]{4x^2-12x+7}+\sqrt[3]{(4x^2-12x+7)^2}\right]}$$

$$=\lim_{x\to2}\frac{1}{\left[(x-1)^2+(x-1)\sqrt[3]{4x^2-12x+7}+\sqrt[3]{(4x^2-12x+7)^2}\right]}=\frac{1}{3}$$

ដូចនេះ $L=\dfrac{1}{3}$ ។

ច.ករណីកន្សោមរាង $\sqrt[3]{A}-\sqrt[3]{B}$

គេមាន $(\sqrt[3]{A}-\sqrt[3]{B})(\sqrt[3]{A^2}+\sqrt[3]{A}.\sqrt[3]{B}+\sqrt[3]{B^2})=A-B$

គេបាន $\sqrt[3]{A}-\sqrt[3]{B}=\dfrac{A-B}{\sqrt[3]{A^2}+\sqrt[3]{A}\sqrt[3]{B}+\sqrt[3]{B^2}}$

ឧទាហរណ៍ គណនាលីមីត $\lim\limits_{x\to1}\dfrac{\sqrt[3]{x^3-2x^2}-\sqrt[3]{x^2-3x+1}}{(x-1)^3}$?

ដំណោះស្រាយ

យក $L=\lim\limits_{x\to1}\dfrac{\sqrt[3]{x^3-2x^2}-\sqrt[3]{x^2-3x+1}}{(x-1)^3}$

$$=\lim_{x\to1}\frac{(x^3-2x^2)-(x^2-3x+1)}{(x-1)^3\left[\sqrt[3]{(x^3-2x^2)^2}+\sqrt[3]{(x^3-2x^2)(x^2-3x+1)}+\sqrt[3]{(x^2-3x+1)^2}\right]}$$

$$=\lim_{x\to1}\frac{(x-1)^3}{(x-1)^3\left[\sqrt[3]{(x^3-2x^2)^2}+\sqrt[3]{(x^3-2x^2)(x^2-3x+1)}+\sqrt[3]{(x^2-3x+1)^2}\right]}$$

$$=\lim_{x\to1}\frac{1}{\left[\sqrt[3]{(x^3-2x^2)^2}+\sqrt[3]{(x^3-2x^2)(x^2-3x+1)}+\sqrt[3]{(x^2-3x+1)^2}\right]}=\frac{1}{3}$$

ដូចនេះ $L=\lim\limits_{x\to1}\dfrac{\sqrt[3]{x^3-2x^2}-\sqrt[3]{x^2-3x+1}}{(x-1)^3}=\dfrac{1}{3}$ ។

ឆ.ករណីកន្សោមរាង $\sqrt[3]{A}+\sqrt[3]{B}$

គេមាន $(\sqrt[3]{A}+\sqrt[3]{B})(\sqrt[3]{A^2}-\sqrt[3]{A}.\sqrt[3]{B}+\sqrt[3]{B^2})=A+B$

នោះគេបាន $\sqrt[3]{A}+\sqrt[3]{B}=\dfrac{A+B}{\sqrt[3]{A^2}-\sqrt[3]{A}\sqrt[3]{B}+\sqrt[3]{B^2}}$

ឧទាហរណ៍ គណនាលីមីត $\lim\limits_{x\to-2}\dfrac{\sqrt[3]{x^2+4}+\sqrt[3]{4x}}{(x+2)^2}$ ។

ដំណោះស្រាយ

តាង $L = \lim\limits_{x\to -2}\dfrac{\sqrt[3]{x^2+4}+\sqrt[3]{4x}}{(x+2)^2}$

$$= \lim_{x\to -2}\frac{(x^2+4)+(4x)}{(x+2)^2\left[\sqrt[3]{(x^2+4)^2}-\sqrt[3]{4x(x^2+4)}+\sqrt[3]{(4x)^2}\right]}$$

$$= \lim_{x\to -2}\frac{(x+2)^2}{(x+2)^2\left[\sqrt[3]{(x^2+4)^2}-\sqrt[3]{4x(x^2+4)}+\sqrt[3]{(4x)^2}\right]}$$

$$\lim_{x\to -2}\frac{1}{\left[\sqrt[3]{(x^2+4)^2}-\sqrt[3]{4x(x^2+4)}+\sqrt[3]{(4x)^2}\right]}=\frac{1}{12}$$

ដូចនេះ $\lim\limits_{x\to -2}\dfrac{\sqrt[3]{x^2+4}+\sqrt[3]{4x}}{(x+2)^2}=\dfrac{1}{12}$ ។

៣.របៀបគណនាលីមីតត្រង់អនន្ត

□ រូបមន្តសំខាន់ៗ

ក. $\lim\limits_{x\to\pm\infty} ax^2 = \begin{cases} +\infty & \text{បើ } a>0 \\ -\infty & \text{បើ } a<0 \end{cases}$

ខ. $\lim\limits_{x\to\pm\infty}\dfrac{a}{x}=0$, $a\in\mathbb{R}$

☑ របៀបគណនាលីមីតត្រង់អនន្តចំពោះកន្សោមរាង ៖

$$L=\lim_{x\to\infty}\frac{a_m x^m + a_{m-1}x^{m-1}+....+a_1x+a_0}{b_n x^n + b_{n-1}x^{n-1}+.....+b_1x+b_0}$$

ដើម្បីគណនាលីមីតនេះគេត្រូវ

✓ ដាក់តួ x ដែលមានស្វ័យគុណខ្ពស់ជាងគេជាកត្តារួម

✓ សម្រួលកត្តា x នោះចោល

✓ គណនាលីមីតដោយប្រើរូបមន្ត $\lim\limits_{x\to\infty}\dfrac{1}{x^\alpha}=0,\ \alpha>0$

ឧទាហរណ៍ គណនាលីមីត $\lim_{x\to\infty}\frac{8x^7-3x^4+x+2}{2x^7+7x-3}$?

ដំណោះស្រាយ

យើងតាង $L=\lim_{x\to\infty}\frac{8x^7-3x^4+x+2}{2x^7+7x-3}$

$$=\lim_{x\to\infty}\frac{x^7(8-\frac{3}{x^3}+\frac{1}{x^6}+\frac{2}{x^7})}{x^7(2+\frac{7}{x^6}-\frac{3}{x^7})}$$

$$=\lim_{x\to\infty}\frac{8-\frac{3}{x^3}+\frac{1}{x^6}+\frac{2}{x^7}}{2+\frac{7}{x^6}-\frac{3}{x^7}}=\frac{8}{2}=4$$

ដូចនេះ $L=\lim_{x\to\infty}\frac{8x^7-3x^4+x+2}{2x^7+7x-3}=4$ ។

សម្គាល់ គេអាចគណនាតាមរបៀបខាងក្រោម ៖

$$L=\lim_{x\to\infty}\frac{8x^7-3x^4+x+2}{2x^7+7x-3}=\lim_{x\to\infty}\frac{8x^7}{2x^7}=\frac{8}{2}=4 \text{ ។}$$

✧ **របៀបគណនាលីមីតត្រង់អនន្តចំពោះកន្សោមអសនិទាន**

គេត្រូវប្រើរូបមន្តបំលែងដូចខាងក្រោម ៖

ក. $\sqrt{A}-\sqrt{B}=\frac{A-B}{\sqrt{A}+\sqrt{B}}$

ខ. $\sqrt[3]{A}-\sqrt[3]{B}=\frac{A-B}{\sqrt[3]{A^2}+\sqrt[3]{A}.\sqrt[3]{B}+\sqrt[3]{B^2}}$

គ. $\sqrt[3]{A}+\sqrt[3]{B}=\frac{A+B}{\sqrt[3]{A^2}-\sqrt[3]{A}.\sqrt[3]{B}+\sqrt[3]{B^2}}$

☐ ឃ. $\sqrt[n]{A}-\sqrt[n]{B}=\frac{A-B}{\sqrt[n]{A^{n-1}}+\sqrt[n]{A^{n-2}B}+\ldots+\sqrt[n]{B^{n-1}}}$

ឧទាហរណ៍ គណនាលីមីត $\lim_{x\to+\infty}(\sqrt{x^2+7x+1}-\sqrt{x^2+4})$ ។

ដំណោះស្រាយ

គេបាន $\lim_{x\to+\infty}(\sqrt{x^2+7x+1}-\sqrt{x^2+4})=\lim_{x\to+\infty}\frac{x^2+7x+1-x^2-4}{\sqrt{x^2+7x+1}+\sqrt{x^2+4}}$

$$=\lim_{x\to+\infty}\frac{7x-3}{x\sqrt{1+\frac{7}{x}+\frac{1}{x^2}}+x\sqrt{1+\frac{4}{x^2}}}$$

$$=\lim_{x\to+\infty}\frac{7-\frac{3}{x}}{\sqrt{1+\frac{7}{x}+\frac{1}{x^2}}+\sqrt{1+\frac{4}{x^2}}}=\frac{7}{2}$$

✧ របៀបគណនាលីមីតត្រង់អនន្តចំពោះកន្សោមជាផលបូកនៃស្វ៊ីតចំនួនពិត

រូបមន្តផលបូកស្វ៊ីតសំខាន់ៗ ៖

ក. $1+2+3+......+n=\frac{n(n+1)}{2}$

ខ. $1^2+2^2+3^2+.....+n^2=\frac{n(n+1)(2n+1)}{6}$

គ. $1^3+2^3+3^3+....+n^3=\frac{n^2(n+1)^2}{4}$

ឃ. ផលបូកស្វ៊ីតនព្វន្ត

$$S_n=a_1+a_2+a_3+....+a_n=\frac{n(a_1+a_n)}{2}$$

ង. ផលបូកស្វ៊ីតធរណីមាត្រ

$$S_n=a_1+a_2+a_3+....+a_n=a_1\times\frac{1-q^n}{1-q}$$ ។

ឧទាហរណ៍ គណនាលីមីត $\lim_{n\to+\infty}\frac{1+2+3+....+n}{n^2}$ ។

ដំណោះស្រាយ

យើងបាន $\lim_{n\to+\infty}\frac{1+2+3+...+n}{n^2}=\lim_{n\to+\infty}\frac{n(n+1)}{2n^2}$

$=\lim_{n\to+\infty}\frac{n+1}{2n}=\lim_{n\to+\infty}\frac{n}{2n}=\frac{1}{2}$ ។

ដូចនេះ: $\lim_{n\to+\infty}\frac{1+2+3+....+n}{n^2}=\frac{1}{2}$ ។

ឧទាហរណ៍ គណនាលីមីត $\lim_{n\to+\infty}\frac{1^2+2^2+3^2+....+n^2}{n^3}$ ។

ដំណោះស្រាយ

យើងបាន $\lim_{n\to+\infty}\frac{1^2+2^2+3^2+...+n^2}{n^3}=\lim_{n\to+\infty}\frac{n(n+1)(2n+1)}{6n^3}$

$=\lim_{n\to+\infty}\frac{(n+1)(2n+1)}{6n^2}$

$=\lim_{n\to+\infty}\frac{(1+\frac{1}{n})(2+\frac{1}{n})}{6}=\frac{2}{6}=\frac{1}{3}$

ដូចនេះ: $\lim_{n\to+\infty}\frac{1^2+2^2+3^2+....+n^2}{n^3}=\frac{1}{3}$ ។

៤.របៀបគណនាលីមីតអនុគមន៍ត្រីកោណមាត្រ

រូបមន្តអនុគមន៍ត្រីកោណមាត្រដែលគួរចងចាំ

$A)$ ទំនាក់ទំនងគ្រឹះ

ក. $\sin^2\theta+\cos^2\theta=1$ ខ. $\tan\theta=\frac{\sin\theta}{\cos\theta}$ គ. $\cot\theta=\frac{\cos\theta}{\sin\theta}$

ឃ. $1+\tan^2\theta=\frac{1}{\cos^2\theta}$ ង. $1+\cot^2\theta=\frac{1}{\sin^2\theta}$ ច. $\tan\theta=\frac{1}{\cot\theta}$

$B)$ រូបមន្តបំលែងមុំផ្ស

ក.មុំផ្ទុយគ្នា θ និង $-\theta$

$$\begin{cases} \sin(-\theta) = -\sin\theta \\ \cos(-\theta) = \cos\theta \\ \tan(-\theta) = -\tan\theta \\ \cot(-\theta) = -\cot\theta \end{cases}$$

ខ.មុំបំពេញគ្នា $(\frac{\pi}{2}-\theta)$ និង θ

$$\begin{cases} \sin(\frac{\pi}{2}-\theta) = \cos\theta \\ \cos(\frac{\pi}{2}-\theta) = \sin\theta \\ \tan(\frac{\pi}{2}-\theta) = \cot\theta \\ \cot(\frac{\pi}{2}-\theta) = \tan\theta \end{cases}$$

គ.មុំបន្ថែមគ្នា $\pi-\theta$ និង θ

$$\begin{cases} \sin(\pi-\theta) = \sin\theta \\ \cos(\pi-\theta) = -\cos\theta \\ \tan(\pi-\theta) = -\tan\theta \\ \cot(\pi-\theta) = -\cot\theta \end{cases}$$

ឃ.មុំមានផលសងស្មើនឹង π

$$\begin{cases} \sin(\pi+\theta) = -\sin\theta \\ \cos(\pi+\theta) = -\cos\theta \\ \tan(\pi+\theta) = \tan\theta \\ \cot(\pi+\theta) = \cot\theta \end{cases}$$

ង.មុំមានផលសងស្មើនឹង $\frac{\pi}{2}$

$$\begin{cases} \sin(\frac{\pi}{2}+\theta) = \cos\theta \\ \cos(\frac{\pi}{2}+\theta) = -\sin\theta \\ \tan(\frac{\pi}{2}+\theta) = -\cot\theta \\ \cot(\frac{\pi}{2}+\theta) = -\tan\theta \end{cases}$$

$C)$ រូបមន្តផលបូកនិងផលដករវាងមុំពីរ

ក. $\cos(a-b)=\cos a\cos b+\sin a\sin b$

ខ. $\cos(a+b)=\cos a\cos b-\sin a\sin b$

គ. $\sin(a+b)=\sin a\cos b+\sin b\cos a$

ឃ. $\sin(a-b)=\sin a\cos b-\sin b\cos a$

ង. $\tan(a\pm b)=\dfrac{\tan a\pm\tan b}{1\mp\tan a\tan b}$

$D)$ រូបមន្តមុំឌុប

ក. $\sin 2a=\sin a\cos a$

ខ. $\cos 2a=\cos^2 a-\sin^2 a=2\cos^2 a-1=1-2\sin^2 a$

គ. $\tan 2a=\dfrac{2\tan a}{1-\tan^2 a}$

$E)$ រូបមន្តបំលែងពីផលគុណទៅផលបូក

ក. $\sin a\cos b=\dfrac{1}{2}\left[\sin(a+b)+\sin(a-b)\right]$

ខ. $\sin b\cos a=\dfrac{1}{2}\left[\sin(a+b)-\sin(a-b)\right]$

គ. $\cos a\cos b=\dfrac{1}{2}\left[\cos(a+b)+\cos(a-b)\right]$

ឃ. $\sin a\sin b=-\dfrac{1}{2}\left[\cos(a+b)-\cos(a-b)\right]$

$F)$ រូបមន្តបំលែងពីផលគុណទៅផលបូក

ក. $\sin p+\sin q=2\sin\dfrac{p+q}{2}\cos\dfrac{p-q}{2}$

ខ. $\sin p-\sin q=2\sin\dfrac{p-q}{2}\cos\dfrac{p+q}{2}$

គ. $\cos p+\cos q=2\cos\dfrac{p+q}{2}\cos\dfrac{p-q}{2}$

ឃ. $\cos p-\cos q=-2\sin\frac{p-q}{2}\sin\frac{p+q}{2}$

ង. $\tan p+\tan q=\frac{\sin(p+q)}{\cos p\cos q}$

ច. $\tan p-\tan q=\frac{\sin(p-q)}{\cos p\cos q}$

ឆ. $\cot p+\cot q=\frac{\sin(p+q)}{\sin p\sin q}$

ជ. $\cot p-\cot q=-\frac{\sin(p-q)}{\sin p\sin q}$

G) **កន្សោម** $\sin 3a$, $\cos 3a$ **និង** $\tan 3a$

ក. $\sin 3a=3\sin a-4\sin^3 a$

ខ. $\cos 3a=4\cos^3 a-3\cos a$

គ. $\tan 3a=\frac{3\tan a-\tan^3 a}{1-3\tan^2 a}$

H) **អនុគមន៍ត្រីកោណមាត្រនៃមុំ** $\theta+2k\pi$ **និង** θ

ក. $\sin(\theta+2k\pi)=\sin\theta$

ខ. $\cos(\theta+2k\pi)=\cos\theta$

គ. $\tan(\theta+2k\pi)=\tan\theta$

ឃ. $\cot(\theta+2k\pi)=\cot\theta$ (ដែល k ជាចំនួនគត់រឺឡាទីហ្វ)។

✧ **ស្រាយបំភ្លឺគណនាដោយប្រើរូបមន្តគ្រឹះ**

ក. $\lim_{x\to 0}\frac{\sin x}{x}=\lim_{x\to 0}\frac{x}{\sin x}=1$

ខ. $\lim_{x\to 0}\frac{\tan x}{x}=\lim_{x\to 0}\frac{x}{\tan x}=1$

គ. $\lim_{x\to 0}\frac{1-\cos x}{x}=0$

☐ ឧទាហរណ៍ គណនាលីមីត

ក. $\lim_{x\to0}\frac{1-\cos x+\sin x}{x}=\lim_{x\to0}\frac{1-\cos x}{x}+\lim_{x\to0}\frac{\sin x}{x}=0+1=1$

ខ. $\lim_{x\to0}\frac{1-\cos x}{x^2}=\lim_{x\to0}\frac{2\sin^2\frac{x}{2}}{x^2}=\frac{1}{2}\lim_{x\to0}\left(\frac{\sin\frac{x}{2}}{\frac{x}{2}}\right)^2=\frac{1}{2}\times1^2=\frac{1}{2}$

គ. $\lim_{x\to0}\frac{x+\tan x}{x+\tan 3x}=\lim_{x\to0}\frac{1+\frac{\tan x}{x}}{1+\frac{\tan 3x}{3x}.3}=\frac{1+1}{1+3}=\frac{1}{2}$ ។

ឃ. $\lim_{x\to0}\frac{\sin\left[\sin(\sin x)\right]}{x}=\lim_{x\to0}\frac{\sin\left[\sin(\sin x)\right]}{\sin(\sin x)}.\frac{\sin(\sin x)}{\sin x}.\frac{\sin x}{x}=1$

ង. $\lim_{x\to0}\frac{\sin x\sin 2x\sin 3x....\sin(nx)}{x^n}$

$=\lim_{x\to0}\frac{\sin x}{x}.2\frac{\sin 2x}{2x}.3\frac{\sin 3x}{3x}....n.\frac{\sin(nx)}{nx}=1\times2\times3\times....\times n=n!$

✧ របៀបគណនាត្រីកោណមាត្រដោយប្រើរូបមន្តប្តូរអថេរ

ឧបមាថាគេមានលីមីត $L=\lim_{x\to a}\left[f(x)\right]$ ដែល $a\neq0$

គេតាង $t=a-x\Rightarrow x=a-t$ កាលណា $x\to a$ នោះ $t\to0$

គេបានរូបមន្ត $L=\lim_{x\to a}\left[f(x)\right]=\lim_{t\to0}\left[f(a-t)\right]$ (ហៅថារូបមន្តប្តូរអថេរ)។

ឧទាហរណ៍ គណនាលីមីត $L=\lim_{x\to\frac{\pi}{2}}\frac{1-\sin x}{(\frac{\pi}{2}-x)^2}$

ដំណោះស្រាយ

យើងតាង $\frac{\pi}{2}-x=t$ នោះ $x=\frac{\pi}{2}-t$

បើ $x\to\frac{\pi}{2}$ នោះ $t\to0$

គេបាន $L=\lim_{t\to 0}\dfrac{1-\sin(\frac{\pi}{2}-t)}{t^2}=\lim_{t\to 0}\dfrac{1-\cos t}{t^2}=\lim_{t\to 0}\dfrac{\sin^2 t}{t^2}.\dfrac{1}{1+\cos t}=\dfrac{1}{2}$ ។

ដូចនេះ $L=\lim_{x\to\frac{\pi}{2}}\dfrac{1-\sin x}{(\frac{\pi}{2}-x)^2}=\dfrac{1}{2}$ ។

ឧទាហរណ៍ គណនាលីមីត $A=\lim_{x\to 1}\dfrac{1-\cos(2\pi x)}{(1-x)^2}$ ។

ដំណោះស្រាយ

គណនា $A=\lim_{x\to 1}\dfrac{1-\cos(2\pi x)}{(1-x)^2}$ ដោយ $1-\cos(2\pi x)=2\sin^2(\pi x)$

គេបាន $A=\lim_{x\to 1}\dfrac{2\sin^2(\pi x)}{(1-x)^2}$

តាង $u=1-x$ នោះ $x=1-u$ ហើយកាលណា $x\to 1$ នោះ $u\to 0$

គេបាន $A=2\lim_{u\to 0}\dfrac{\sin^2(\pi-\pi u)}{u^2}=2\lim_{u\to 0}\dfrac{\sin^2(\pi u)}{u^2}$

$$=2\lim_{u\to 0}\left[\frac{\sin(\pi u)}{(\pi u)}\times\pi\right]^2=2\pi^2$$

ដូចនេះ $A=2\pi^2$ ។

ឧទាហរណ៍ ចូរគណនាលីមីត $A=\lim_{x\to\frac{\pi}{3}}\dfrac{2\sin(x-\frac{\pi}{3})}{3x-\pi}$ ។

ដំណោះស្រាយ

គណនា $A=\lim_{x\to\frac{\pi}{3}}\dfrac{2\sin(x-\frac{\pi}{3})}{3x-\pi}$

តាង $u=x-\frac{\pi}{3}$ នោះ $x=\frac{\pi}{3}+u$ ។ កាលណា $x\to\frac{\pi}{3}$ នោះ $u\to 0$

គេបាន $A=\lim_{u\to 0}\frac{2\sin u}{3(\frac{\pi}{3}+u)-\pi}=\lim_{u\to 0}\frac{2\sin u}{3u}=\frac{2}{3}\lim_{u\to 0}\frac{\sin u}{u}=\frac{2}{3}$

ដូចនេះ $A=\lim_{x\to\frac{\pi}{3}}\frac{2\sin(x-\frac{\pi}{3})}{3x-\pi}=\frac{2}{3}$ ។

ឧទាហរណ៍ ចូរគណនាលីមីត $A=\lim_{x\to\pi}(\pi^2-x^2)\tan\frac{x}{2}$ ។

ដំណោះស្រាយ

គណនា $A=\lim_{x\to\pi}(\pi^2-x^2)\tan\frac{x}{2}$

តាង $u=\pi-x$ នោះ $x=\pi-u$ ។ កាលណា $x\to\pi$ នោះ $u\to 0$

គេបាន $A=\lim_{x\to\pi}\left[\pi^2-(\pi-u)^2\right]\tan\left(\frac{\pi}{2}-\frac{u}{2}\right)$

$$=\lim_{x\to\pi}\left(2\pi u-u^2\right)\cot\frac{u}{2}$$

$$=\lim_{x\to\pi}[u(2\pi-u)\frac{1}{\tan\frac{u}{2}}]$$

$$=\lim_{x\to\pi}[\ 2(2\pi-\mathrm{u})\frac{\frac{u}{2}}{\tan\frac{u}{2}}\ ]=4\pi$$

ដូចនេះ $A=\lim_{x\to\pi}(\pi^2-x^2)\tan\frac{x}{2}=4\pi$

ឧទាហរណ៍ ចូរគណនាលីមីត $A=\lim\limits_{x\to\infty}(2x+1)\sin\left(\dfrac{\pi x}{x+2}\right)$ ។

ដំណោះស្រាយ

គណនា $A=\lim\limits_{x\to\infty}(2x+1)\sin\left(\dfrac{\pi x}{x+2}\right)$

គេមាន $\dfrac{\pi x}{x+2}=\dfrac{\pi(x+2)-2\pi}{x+2}=\pi-\dfrac{2\pi}{x+2}$

នោះ $\sin\left(\dfrac{\pi x}{x+2}\right)=\sin\left(\pi-\dfrac{2\pi}{x+2}\right)=\sin\left(\dfrac{2\pi}{x+2}\right)$

គេបាន $A=\lim\limits_{x\to\infty}(2x+1)\sin\left(\dfrac{2\pi}{x+2}\right)$

តាង $u=\dfrac{2\pi}{x+2}$ នោះ $x=\dfrac{2\pi-2u}{u}$

កាលណា $x\to\infty$ នោះ $u\to 0$

គេបាន $A=\lim\limits_{u\to 0}\left[2\left(\dfrac{2\pi-2u}{u}\right)+1\right]\sin u$

$$=\lim_{u\to 0}\frac{4\pi-4u+u}{u}\sin u$$

$$=\lim_{u\to 0}(4\pi-3u)\frac{\sin u}{u}=4\pi$$

ដូចនេះ $A=\lim\limits_{x\to\infty}(2x+1)\sin\left(\dfrac{\pi x}{x+2}\right)=4\pi$ ។

៥.លីមីតនៃអនុគមន៍អិចស្ប៉ូណង់ស្យែល

រូបមន្តសំខាន់ៗគួរកត់សម្គាល់៖

ក. $\lim\limits_{x\to 0}\dfrac{e^x-1}{x}=1$

ខ. $\lim\limits_{x\to 0}\dfrac{a^x-1}{x}=\ln a \quad ,(a>0)$

គ. $\lim_{x\to 0}(1+x)^{\frac{1}{x}} = \lim_{x\to\infty}\left(1+\frac{1}{x}\right)^{x} = e$

ឃ. $\lim_{x\to+\infty} a^{x} = \begin{cases} +\infty & \text{បើ } a>1 \\ 0 & \text{បើ } 0<a<1 \end{cases}$

ឧទាហរណ៍ គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to 0}\frac{e^{\sin x}-1}{x} = \lim_{x\to 0}\frac{e^{\sin x}-1}{\sin x}\times\frac{\sin x}{x} = 1\times 1 = 1$

ខ. $\lim_{x\to 0}\frac{e^{x^2}-\cos 2x}{x^2} = \lim_{x\to 0}\frac{e^{x^2}-(1-2\sin^2 x)}{x^2}$

$$= \lim_{x\to 0}\frac{e^{x^2}-1}{x^2} + 2\lim_{x\to 0}\left(\frac{\sin x}{x}\right)^2$$

$$= 1 + 2\times 1^2 = 3$$

គ. $\lim_{x\to 0}\frac{e^{ax}-e^{bx}}{x} = \lim_{x\to 0}\frac{e^{ax}-1}{ax}\times a - \lim_{x\to 0}\frac{e^{bx}-1}{bx}\times b$

$$= a-b \ , \ a,b\in\mathbb{R}^*$$

ដូចនេះ $\lim_{x\to 0}\frac{e^{ax}-e^{bx}}{x} = a-b$ ។

៦.លីមីតនៃអនុគមន៍លោការីត

រូបមន្តសំខាន់ៗ៖

ក. $\lim_{x\to 0}\frac{\ln(1+x)}{x} = 1$

ខ. $\lim_{x\to 0^+}\ln x = -\infty$

គ. $\lim_{x\to+\infty}\ln x = +\infty$

ឧទាហរណ៍ គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to 0}\frac{\ln(1+\tan 2x)}{x} = \lim_{x\to 0}\frac{\ln(1+\tan 2x)}{\tan 2x}.\frac{\tan 2x}{2x}.2 = 2$

ខ. $\lim_{x\to 0}\frac{\ln(\cos 2x)}{x^2}=\lim_{x\to 0}\frac{\ln(1-2\sin^2 x)}{x^2}$

$=\lim_{x\to 0}\frac{\ln(1-2\sin^2 x)}{(-2\sin^2 x)}\times\frac{\sin^2 x}{x^2}\times(-2)=-2$

គ. $\lim_{x\to 0}\frac{\ln(1+4x-x^2)}{x}=\lim_{x\to 0}\frac{\ln(1+4x-x^2)}{4x-x^2}\times\frac{4x-x^2}{x}$

$=\lim_{x\to 0}\frac{\ln(1+4x-x^2)}{4x-x^2}.(4-x)=1\times 4=4$

ឃ. $\lim_{x\to 0}\frac{\ln(3-2e^x)}{x}=\lim_{x\to 0}\frac{\ln(1+2(1-e^x)]}{2(1-e^x)}\times\frac{-2(e^x-1)}{x}=-2$

៧.របៀបគណនាលីមីតរាងមិនកំណត់ 1^∞

កាលណា $x\to x_0$ គេមាន $f(x)\to 0$ និង $g(x)\to\infty$ នោះលីមីត $\lim_{x\to x_0}[f(x)]^{g(x)}$ មានរាងមិនកំនត់ 1^∞ ។

ដើម្បីគណនាលីមីតនេះគេត្រូវប្រើរូបមន្តគ្រឹះ

$a)\ \lim_{x\to 0}(1+x)^{\frac{1}{x}}=e$ $\quad b)\ \lim_{x\to\infty}\left(1+\frac{1}{x}\right)^x=e$ ដែល $e=2.7182818...$ ។

ឧទាហរណ៍ គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to 0}\left(1+\frac{x}{2}\right)^{\frac{1}{x}}=\lim_{x\to 0}\left[\left(1+\frac{x}{2}\right)^{\frac{1}{x/2}}\right]^{\frac{1}{2}}=e^{\frac{1}{2}}=\sqrt{e}$

ខ. $\lim_{x\to 0}\left(1+\sin\frac{x}{2}\right)^{\frac{1}{x}}=\lim_{x\to 0}\left[\left(1+\sin\frac{x}{2}\right)^{\frac{1}{\sin\frac{x}{2}}}\right]^{\frac{\sin\frac{x}{2}}{\frac{x}{2}}.\frac{1}{2}}=e^{\frac{1}{2}}=\sqrt{e}$

គ. $\lim_{x\to+\infty}\left(1+\frac{2}{x}\right)^{x}=\left[\left(1+\frac{2}{x}\right)^{\frac{x}{2}}\right]^{2}=e^{2}$

ឃ. $\lim_{x\to+\infty}\left(\frac{x-1}{x+1}\right)^{x}=\lim_{x\to+\infty}\left[1+\left(\frac{-2}{x+1}\right)^{\frac{x+1}{-2}}\right]^{\frac{-2x}{x+1}}=e^{-2}=\frac{1}{e^{2}}$ ។

ង. $\lim_{x\to 0}\left(\frac{x^{2}-x+1}{x^{2}+x+1}\right)^{\frac{1}{\sin x}}$

គេមាន $\frac{x^{2}-x+1}{x^{2}+x+1}=1+\left(\frac{x^{2}-x+1}{x^{2}+x+1}-1\right)=1+\frac{-2x}{x^{2}+x+1}$

$$\lim_{x\to 0}\left(\frac{x^{2}-x+1}{x^{2}+x+1}\right)^{\frac{1}{\sin x}}=\lim_{x\to 0}\left(1+\frac{-2x}{x^{2}+x+1}\right)^{\frac{1}{\sin x}}$$

$$=\lim_{x\to 0}\left[\left(1+\frac{-2x}{x^{2}+x+1}\right)^{\frac{x^{2}+x+1}{-2x}}\right]^{-\frac{x}{\sin x}\cdot\frac{2}{x^{2}+x+1}}$$

$$=e^{-2}=\frac{1}{e^{2}}$$

ដូចនេះ $\lim_{x\to 0}\left(\frac{x^{2}-x+1}{x^{2}+x+1}\right)^{\frac{1}{\sin x}}=\frac{1}{e^{2}}$ ។

៨.របៀបគណនាលីមីតរាងមិនកំនត់ដោយប្រើទ្រឹស្តីបទឡូពីតាល់

ក.ទ្រឹស្តីបទ

សន្មតថាគេមានអនុគមន៍ពីរ f និង g មានដេរីវេត្រង់ $x=x_0$ ហើយ $g'(x_0)\neq 0$ ។

.បើ $\lim_{x\to x_0}\frac{f(x)}{g(x)}$ មានរាង $\frac{0}{0}$ ឬ $\frac{\infty}{\infty}$ នោះ $\lim_{x\to x_0}\frac{f(x)}{g(x)}=\lim_{x\to x_0}\frac{f'(x)}{g'(x)}=\frac{f'(x_0)}{g'(x_0)}$ ។

.បើ $\lim\limits_{x\to x_0}\frac{f'(x)}{g'(x)}$ មានរាងមិនកំនត់ $\frac{0}{0}$ ឬ $\frac{\infty}{\infty}$ ដដែលហើយផលធៀប $\frac{f''(x)}{g''(x)}$ ផ្ទៀងផ្ទាត់លក្ខខណ្ឌឡូពីតាល់នោះគេអាចអនុវត្តន៍តាមវិធានទូទៅដូចខាងក្រោម ៖

$$\lim_{x\to x_0}\frac{f(x)}{g(x)}=\lim_{x\to x_0}\frac{f'(x)}{g'(x)}=\lim_{x\to x_0}\frac{f''(x)}{g''(x)}=....=\lim_{x\to x_0}\frac{f^{(n)}(x)}{g^{(n)}(x)}$$ ។

ខ.រូបមន្តដេរីវេសំខាន់ៗ

អនុគមន៍	ដេរីវេ
ក. $y=k$	$y'=0$
ខ. $y=x^n$	$y'=nx^{n-1}$
គ. $y=\frac{1}{x}$	$y'=-\frac{1}{x^2}$
ឃ. $y=\sqrt{x}$	$y'=\frac{1}{2\sqrt{x}}$
ង. $y=e^x$	$y'=e^x$
ច. $y=a^x$	$y'=a^x\ln a$
ឆ. $y=\ln x$	$y'=\frac{1}{x}$
ជ. $y=\sin x$	$y=\cos x$
ឈ. $y=\cos x$	$y'=-\sin x$
ញ. $y=\tan x$	$y'=\frac{1}{\cos^2 x}=1+\tan^2 x$
ដ. $y=\cot x$	$y'=-\frac{1}{\sin^2 x}$
ឋ. $y=\arcsin x$	$y'=\frac{1}{\sqrt{1-x^2}}$
ឲ. $y=\arccos x$	$y'=-\frac{1}{\sqrt{1-x^2}}$
ឍ. $y=\arctan x$	$y'=\frac{1}{1+x^2}$

គ.រូបមន្តដេរីវេផ្សេងៗទៀត

អនុគមន៍	ដេរីវេ
ក. $y = u^n$	$y' = n.u'.u^{n-1}$
ខ. $y = \sqrt{u}$	$y' = \dfrac{u'}{2\sqrt{u}}$
គ. $y = u.v$	$y' = u'v + v'u$
ឃ. $y = \dfrac{u}{v}$	$y' = \dfrac{u'v - v'u}{v^2}$
ង. $y = \ln u$	$y' = \dfrac{u'}{u}$
ច. $y = \sin u$	$y' = u'.\cos u$
ឆ. $y = \cos u$	$y' = -u'\sin u$
ជ. $y = e^u$	$y' = u'.e^u$
ឈ. $y = \tan u$	$y' = u'(1 + \tan^2 u)$
ញ. $y = \arcsin u$	$y' = \dfrac{u'}{\sqrt{1-u^2}}$
ដ. $y = \arccos u$	$y' = -\dfrac{u'}{\sqrt{1-u^2}}$
ឋ. $y = \arctan u$	$y' = \dfrac{u'}{1+u^2}$

ឧទាហរណ៍ គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to 1} \dfrac{2x^5 + 3x^4 - 5}{x^2 - 1}$ មានរាង $\dfrac{0}{0}$

$$= \lim_{x\to 1} \frac{(2x^5 + 3x^4 - 5)'}{(x^2 - 1)'}$$

$$= \lim_{x\to 1} \frac{10x^4 + 12x^3}{2x} = \frac{10 + 12}{2} = 11$$

ដូចនេះ $\lim\limits_{x\to 1} \dfrac{2x^5 + 3x^4 - 5}{x^2 - 1} = 11$ ។

ខ. $\lim_{x\to 2}\frac{x^4+x^3-x-22}{x^2-4}$ មានរាង $\frac{0}{0}$

$$=\lim_{x\to 2}\frac{(x^4+x^3-x-22)'}{(x^2-4)'}=\lim_{x\to 2}\frac{4x^3+3x^2}{2x}$$

$$=\frac{4(2)^3+3(2)^2}{2(2)}=\frac{32+12}{4}=11$$

ដូចនេះ $\lim_{x\to 2}\frac{x^4+x^3-x-22}{x^2-4}=11$

គ. $\lim_{x\to 1}\frac{x^3-1}{\sqrt{x}-1}$ រាង $\frac{0}{0}$

$$=\lim_{x\to 1}\frac{(x^3-1)'}{(\sqrt{x}-1)'}=\lim_{x\to 1}\frac{3x^2}{\frac{1}{2\sqrt{x}}}=\frac{3}{\frac{1}{2}}=6$$

ដូចនេះ $\lim_{x\to 1}\frac{x^3-1}{\sqrt{x}-1}=6$ ។

ឃ. $\lim_{x\to 1}\frac{\sin\pi x}{x^2-1}$ រាង $\frac{0}{0}$

$$=\lim_{x\to 1}\frac{(\sin\pi x)'}{(x^2-1)'}=\lim_{x\to 1}\frac{\pi\cos\pi x}{2x}=\frac{\pi\cos\pi}{2}=-\frac{\pi}{2}$$

ដូចនេះ $\lim_{x\to 1}\frac{\sin\pi x}{x^2-1}=-\frac{\pi}{2}$ ។

www.mathtoday.wordpress.com

ជំពូកទី០៣

សង្ខេបមេរៀនសិក្សាភាពជាប់នៃអនុគមន៍

១.សញ្ញាណនៃអនុគមន៍ជាប់

កាលណាគេគូសក្រាបនៃអនុគមន៍ $y = f(x)$ លើចន្លោះ I មួយនៃដែនកំណត់ដោយមិនលើកខ្មៅដៃនោះគេបានគំនូសជាខ្សែកោងជាប់គេថាអនុគមន៍ f ជាអនុគមន៍ជាប់ត្រង់គ្រប់ចំណុចនៃចន្លោះ I ។



២.ភាពជាប់ត្រង់មួយចំណុច

និយមន័យ អនុគមន៍ $y = f(x)$ ជាអនុគមន៍ជាប់ត្រង់ $x = a$ កាលណា f បំពេញលក្ខខណ្ឌទាំងបីខាងក្រោម ៖

ក. f កំណត់ចំពោះ $x=a$

ខ. f មានលីមីតកាលណា x ខិតជិត a

គ. $\lim_{x\to a} f(x)=f(a)$ ។

ឧទាហរណ៍ គេឲ្យអនុគមន៍ f កំណត់ដោយ

$$f(x)=\begin{cases}\dfrac{3\sin x-\sin 3x}{x^3} & \text{បើ } x\neq 0\\ 4 & \text{បើ } x=0\end{cases}$$

ចូរសិក្សាភាពជាប់នៃអនុគមន៍ f ត្រង់ $x=0$ ។

ដំណោះស្រាយ

សិក្សាភាពជាប់នៃអនុគមន៍ f ត្រង់ $x=0$

តាមសម្មតិកម្ម $f(x)=\begin{cases}\dfrac{3\sin x-\sin 3x}{x^3} & \text{បើ } x\neq 0\\ 4 & \text{បើ } x=0\end{cases}$

គេមាន $f(0)=4$ កំណត់

គណនា $\lim_{x\to 0} f(x)=\lim_{x\to 0}\dfrac{3\sin x-\sin 3x}{x^3}=\lim_{x\to 0}\dfrac{3\sin x-(3\sin x-4\sin^3 x)}{x^3}$

$$=\lim_{x\to 0}\frac{3\sin x-3\sin x+4\sin^3 x}{x^3}=\lim_{x\to 0}\frac{4\sin^3 x}{x^3}$$

$$=4\lim_{x\to 0}\left(\frac{\sin x}{x}\right)^3=4$$

ដោយ $\lim_{x\to 0} f(x)=f(0)=4$ នោះ f ជាអនុគមន៍ជាប់ត្រង់ $x=0$ ។

ដូចនេះ f ជាអនុគមន៍ជាប់ត្រង់ $x=0$ ។

៣.លក្ខណៈភាពជាប់នៃអនុគមន៍

បើ f និង g ជាអនុគមន៍ជាប់ត្រង់ចំណុច $x=a$ នោះគេបាន ៖

ក. $f(x)+g(x)$ ជាអនុគមន៍ជាប់ត្រង់ ចំណុច $x=a$ ។

ខ. $f(x)-g(x)$ ជាអនុគមន៍ជាប់ត្រង់ ចំណុច $x=a$ ។

គ. $f(x).g(x)$ ជាអនុគមន៍ជាប់ត្រង់ ចំណុច $x=a$ ។

ឃ. $\lambda f(x)$ ជាអនុគមន៍ជាប់ត្រង់ ចំណុច $x=a$ ។ (λ ជាចំនួនពិត)

ង. $\frac{f(x)}{g(x)}$ ជាអនុគមន៍ជាប់ត្រង់ ចំណុច $x=a$ ដែល $g(a)\neq 0$ ។

៤.ភាពជាប់លើចន្លោះ

និយមន័យ ៖

❖ អនុគមន៍ f ជាប់លើចន្លោះបើក (a,b) លុះត្រាតែ f ជាប់ចំពោះគ្រប់តម្លៃ x នៃចន្លោះបើកនោះ ។

❖ អនុគមន៍ f ជាប់លើចន្លោះបិទ $[a,b]$ លុះត្រាតែ f ជាប់លើ (a,b) និងមានលីមីត $\lim_{x\to a^+} f(x)=f(a)$ និង $\lim_{x\to b^-} f(x)=f(b)$ ។

ឧទាហរណ៍ គេឲ្យអនុគមន៍ f កំណត់ដោយ
$$f(x)=\begin{cases} -\frac{\pi}{2} & \text{បើ } x=-1 \\ \frac{\sin \pi x}{1-x^2} & \text{បើ } -1<x<1 \\ \frac{\pi}{2} & \text{បើ } x=1 \end{cases}$$

ចូរសិក្សាភាពជាប់នៃអនុគមន៍ f ជាប់លើចន្លោះ $[-1,1]$ ។

ដំណោះស្រាយ

សិក្សាភាពជាប់នៃអនុគមន៍ f ជាប់លើចន្លោះ $[-1,1]$

គេមាន $f(-1)=-\frac{\pi}{2}$ និង $f(1)=\frac{\pi}{2}$

អនុគមន៍ f ដែល $f(x)=\frac{\sin\pi x}{1-x^2}$ ជាប់លើចន្លោះបើក $(-1,1)$។

យើងមាន $\lim\limits_{x\to -1^+} f(x)=\lim\limits_{x\to -1^+}\frac{\sin\pi x}{1-x^2}$ យក $x=-1-u$

កាលណា $x\to -1^+$ នោះ $u\to 0^-$

គេបាន $\lim\limits_{x\to -1^+} f(x)=\lim\limits_{u\to 0^-}\frac{\sin(-\pi-\pi u)}{1-(-1-u)^2}=\lim\limits_{u\to 0^-}\frac{\sin\pi u}{u(-2-u)}=-\frac{\pi}{2}=f(-1)$

ហើយ $\lim\limits_{x\to 1^-} f(x)=\lim\limits_{x\to 1^-}\frac{\sin\pi x}{1-x^2}$ យក $x=1-u$

កាលណា $x\to 1^-$ នោះ $u\to 0^+$

គេបាន $\lim\limits_{x\to 1^-} f(x)=\lim\limits_{u\to 0^+}\frac{\sin(\pi-\pi u)}{1-(1-u)^2}=\lim\limits_{u\to 0^+}\frac{\sin\pi u}{u(2-u)}=\frac{\pi}{2}=f(1)$

ដោយ $\lim\limits_{x\to -1^+} f(x)=f(-1)$ និង $\lim\limits_{x\to 1^-} f(x)=f(1)$

ដូចនេះ f ជាអនុគមន៍ជាប់លើចន្លោះ $[-1,1]$។

ឧទាហរណ៍ គេឲ្យអនុគមន៍ f កំណត់ដោយ $f(x)=\begin{cases}-\frac{\pi}{2} & \text{បើ } x=0\\ \frac{\sin\pi x}{x^2-2x} & \text{បើ } 0<x<2\\ \frac{\pi}{2} & \text{បើ } x=2\end{cases}$

ចូរសិក្សាភាពជាប់នៃអនុគមន៍ f ជាប់លើចន្លោះ $[0,2]$។

ដំណោះស្រាយ

សិក្សាភាពជាប់នៃអនុគមន៍ f ជាប់លើចន្លោះ $[0,2]$

គេមាន $f(0)=-\frac{\pi}{2}$ និង $f(2)=\frac{\pi}{2}$

អនុគមន៍ f ដែល $f(x)=\frac{\sin \pi x}{x^2-2x}$ ជាប់លើចន្លោះបើក $(0,2)$ ។

យើងមាន $\lim_{x\to 0^+} f(x)=\lim_{x\to 0^+}\frac{\sin \pi x}{x^2-2x}=\lim_{x\to 0^+}\frac{\sin \pi x}{\pi x}\times\frac{\pi}{x-2}=-\frac{\pi}{2}=f(0)$

ហើយ $\lim_{x\to 2^-} f(x)=\lim_{x\to 2^-}\frac{\sin \pi x}{x^2-2x}$ យក $x=2-u$

កាលណា $x\to 2^-$ នោះ $u\to 0^+$

គេបាន $\lim_{x\to 2^-} f(x)=\lim_{u\to 0^+}\frac{\sin(2\pi-\pi u)}{(2-u)^2-2(2-u)}=\lim_{u\to 0^+}\frac{\sin \pi u}{u(2-u)}=\frac{\pi}{2}=f(2)$

ដោយ $\lim_{x\to 0^+} f(x)=f(0)$ និង $\lim_{x\to 2^-} f(x)=f(2)$

ដូចនេះ f ជាអនុគមន៍ជាប់លើចន្លោះ $[0,2]$ ។

៥.ភាពជាប់នៃអនុគមន៍បណ្ដាក់

អនុគមន៍ g ជាប់ត្រង់ $x=a$ និងអនុគមន៍ f ជាប់ត្រង់ $x=g(a)$

នោះអនុគមន៍បណ្ដាក់ $(f\, o\, g)(x)=f[g(x)]$ ជាប់ត្រង់ $x=a$ ។

ឧទាហរណ៍ គេឲ្យអនុគមន៍ g និង f កំណត់ដោយ $g(x)=\frac{4x}{x^2+1}$ និង $f(x)=\ln x$

តើអនុគមន៍ $(f\, o\, g)(x)=f[g(x)]$ ជាប់ត្រង់ $x=1$ ដែរឬទេ ?

ដំណោះស្រាយ

គេមាន $g(1)=\frac{4}{1^2+1}=2$

ហើយ $\lim_{x\to1} g(x) = \lim_{x\to1}\frac{4x}{x^2+1} = \frac{4}{1+1} = 2 = g(1)$ នោះ g ជាអនុគមន៍ជាប់ត្រង់ $x=1$ ។

ហើយបើ $x = g(1) = 2$ នោះ $f(2) = \ln 2$ និង $\lim_{x\to2} f(x) = \lim_{x\to2}\ln x = \ln = f(2)$

នោះ f ជាអនុគមន៍ជាប់ត្រង់ $x=2$ ។

សម្រាយខាងលើបញ្ជាក់ថា $(f\,o\,g)(x) = f[g(x)]$ ជាប់ត្រង់ $x=1$ ។

៦.អនុគមន៍បន្លាយតាមភាពជាប់

បើ f ជាអនុគមន៍មិនកំណត់ត្រង់ $x=a$ និងមានលីមីត $\lim_{x\to a} f(x) = \lambda$

នោះអនុគមន៍បន្លាយនៃ f តាមភាពជាប់ត្រង់ $x=a$ កំណត់ដោយ ៖

$$g(x) = \begin{cases} f(x) & \text{បើ } x \neq a \\ \lambda & \text{បើ } x = a \end{cases}$$

ឧទាហរណ៍ គេឲ្យអនុគមន៍ f កំណត់ដោយ $f(x) = \dfrac{\ln\left(\cos x + \sqrt{1+x^2}\right) - \ln 2}{x^2}$

ដែល $x \neq 0$ ។ រកអនុគមន៍បន្លាយតាមភាពជាប់នៃ f ត្រង់ $x=0$ ។

ដំណោះស្រាយ

រកអនុគមន៍បន្លាយតាមភាពជាប់នៃ f ត្រង់ $x=0$

យើងមាន $\lim_{x\to0} f(x) = \lim_{x\to0}\dfrac{\ln\left(\cos x + \sqrt{1+x^2}\right) - \ln 2}{x^2}$

$$= \lim_{x\to0}\frac{\ln\left[\dfrac{\cos x + \sqrt{1+x^2}}{2}\right]}{x^2}$$

$$= \lim_{x\to0}\frac{\ln\left[1 + \left(\dfrac{\cos x + \sqrt{1+x^2} - 2}{2}\right)\right]}{\dfrac{\cos x + \sqrt{1+x^2} - 2}{2}} \times \lim_{x\to0}\frac{\cos x + \sqrt{1+x^2} - 2}{2x^2}$$

$$= \lim_{x\to 0}\frac{\cos x - 1}{2x^2} + \lim_{x\to 0}\frac{\sqrt{1+x^2}-1}{2x^2}$$

$$= -\frac{1}{2}\lim_{x\to 0}\frac{\sin^2 x}{x^2}\times\frac{1}{1+\cos x} + \frac{1}{2}\lim_{x\to 0}\frac{1}{\sqrt{1+x^2}+1} = -\frac{1}{4}+\frac{1}{4} = 0$$

បើ g ជាអនុគមន៍បន្លាយតាមភាពជាប់នៃ f ត្រង់ $x=0$ នោះគេបាន៖

$$g(x) = \begin{cases} \dfrac{\ln\left(\cos x + \sqrt{1+x^2}\right) - \ln 2}{x^2} & \text{បើ } x \neq 0 \\ 0 & \text{បើ } x = 0 \end{cases}$$

ឧទាហរណ៍ គេឲ្យអនុគមន៍ f កំណត់ដោយ $f(x) = \dfrac{1}{x^2}\ln\left(\dfrac{1}{2}+\sqrt{x^2+\dfrac{1}{4}}\right)$ ដែល $x \neq 0$ ។ ចូររកអនុគមន៍បន្លាយតាមភាពជាប់នៃ f ត្រង់ $x=0$ ។

ដំណោះស្រាយ

រកអនុគមន៍បន្លាយតាមភាពជាប់នៃ f ត្រង់ $x=0$

យើងមាន $\lim\limits_{x\to 0} f(x) = \lim\limits_{x\to 0}\dfrac{1}{x^2}\ln\left(\dfrac{1}{2}+\sqrt{x^2+\dfrac{1}{4}}\right)$

$$= \lim_{x\to 0}\frac{\ln\left(1+\left(\sqrt{x^2+\frac{1}{4}}-\frac{1}{2}\right)\right)}{\left(\sqrt{x^2+\frac{1}{4}}-\frac{1}{2}\right)} \times \lim_{x\to 0}\frac{\sqrt{x^2+\frac{1}{4}}-\frac{1}{2}}{x^2}$$

$$= \lim_{x\to 0}\frac{x^2+\frac{1}{4}-\frac{1}{4}}{x^2\left(\sqrt{x^2+\frac{1}{4}}+\frac{1}{2}\right)} = \lim_{x\to 0}\frac{1}{\sqrt{x^2+\frac{1}{4}}+\frac{1}{2}} = \frac{1}{\frac{1}{2}+\frac{1}{2}} = 1$$

តាង g ជាអនុគមន៍បន្លាយតាមភាពជាប់នៃ f ត្រង់ $x=0$ នោះគេបាន៖

$$g(x)=\begin{cases}\dfrac{1}{x^2}\ln\left(\dfrac{1}{2}+\sqrt{x^2+\dfrac{1}{4}}\right) & \text{បើ } x\neq 0\\ 1 & \text{បើ } x=0\end{cases}$$

៧.ទ្រឹស្តីបទតម្លៃកណ្តាល

ទ្រឹស្តីបទ បើអនុគមន៍ f ជាប់លើចន្លោះបិទ $[a,b]$ និង k ជាចំនួនមួយនៅចន្លោះ $f(a)$ និង $f(b)$ នោះមានចំនួនពិត c មួយយ៉ាងតិចក្នុងចន្លោះបិទ $[a,b]$ ដែល $f(c)=k$ ។

វិបាក បើអនុគមន៍ f ជាប់ហើយកើនដាច់ខាត ឬ ចុះដាច់ខាតលើចន្លោះបិទ $[a,b]$ នោះចំពោះគ្រប់ចំនួន kនៅចន្លោះ $f(a)$ និង $f(b)$សមីការ $f(x)=k$ មានចម្លើយតែមួយគត់នៅចន្លោះ$[a,b]$ ។

សម្រាយបញ្ជាក់



អនុគមន៍ f ជាប់ និង កើនដាច់ខាត លើចន្លោះបិទ$[a,b]$ ។

f ជាអនុគមន៍កើនដាច់ខាតមានន័យថាមានពីរចំនួន α , β នៃ$[a,b]$ដែល $\alpha<\beta$ នាំឲ្យ $f(\alpha)<f(\beta)$ ។ ឲ្យចំនួន k នៅចន្លោះ $f(a)$ និង $f(b)$ ($f(a)<k<f(b)$) និង f ជាអនុគមន៍ជាប់ ។

តាមទ្រឹស្តីបទបញ្ជាក់ថាមានចំនួន c នៅចន្លោះ a និង b ដែល $f(c)=k$ ។

ឧបមាថាមានចំនួន c' មួយទៀតផ្សេងពី c ដែល $f(c')=k$ នោះគេបាន $f(c)=f(c')$ ដែលផ្ទុយពីសម្មតិកម្មដែលថា f ជាអនុគមន៍កើនដាច់ខាត។

ដូចនេះមានចំនួន cតែមួយគត់ដែលផ្ទៀងផ្ទាត់ $f(c)=k$ មានន័យថា សមីការ $f(x)=k$ មានចម្លើយតែមួយគត់ ។

សម្គាល់ ទ្រឹស្តីបទតម្លៃកណ្តាលអាចប្រើបានចំពោះ $k=0$ជាពិសេសបើ f ជាអនុគមន៍ជាប់លើចន្លោះបិទ$[a,b]$ និង $f(a).f(b)<0$ នោះមានចំនួន c មួយយ៉ាងតិចនៃ $[a,b]$ ដែល $f(c)=0$ ។

ឧទាហរណ៍

គេឲ្យសមីការ$(E): ax^2+bx+c=0$ ដែល $ac\neq 0$ និង$a,b,c\in\mathbb{R}$

បើ $7a+4b+c=0$ និង $|a|>|c|$ ចូរស្រាយថាសមីការ(E)មានឫសយ៉ាងតិចមួយស្ថិតនៅក្នុងចន្លោះចំនួន 1 និង 2។

ដំណោះស្រាយ

ស្រាយថាសមីការ(E)មានឫសយ៉ាងតិចមួយស្ថិតនៅក្នុងចន្លោះចំនួន 1 និង 2

គេមាន$(E): ax^2+bx+c=0$ ដែល $ac\neq 0$ និង$a,b,c\in\mathbb{R}$

យក $f(x)=ax^2+bx+c$ ជាអនុគមន៍ជាប់លើ$[1,2]$

យើងមាន $f(1)=a+b+c=-\frac{3}{4}(a-c)+\frac{1}{4}(7a+4b+c)=-\frac{3}{4}(a-c)$

ហើយ $f(2)=4a+2b+c=\frac{1}{2}(a+c)+\frac{1}{2}(7a+4b+c)=\frac{1}{2}(a+c)$

ព្រោះ$7a+4b+c=0$ (តាមបម្រាប់)

យើងបាន $f(1)f(2)=-\frac{3}{8}(a^2-c^2)=-\frac{3}{8}(|a|^2-|c|^2)<0$ព្រោះ$|a|>|c|$

តាមទ្រឹស្តីបទតម្លៃកណ្តាលបញ្ជាក់ថាយ៉ាងហើយណាស់មានចំនួនពិត $x_0\in(1,2)$

ដែល $f(x_0)=0$ ។

ដូចនេះសមីការ(E)មានឫសយ៉ាងតិចមួយស្ថិតនៅក្នុងចន្លោះចំនួន 1 និង 2។

ឧទាហរណ៍

ក.ស្រាយបញ្ជាក់ថាសមីការ $x\tan x=\cos x$ យ៉ាងហោចណាស់មានឫសពិតមួយ

ចន្លោះ $[0,\frac{\pi}{4}]$ ។

ខ.ស្រាយបញ្ជាក់ថាសមីការ $(x^n-1)\cos x+\sqrt{2}\sin x-1=0$

យ៉ាងហោចណាស់មានឫសពិតមួយចន្លោះ $(0,1)$ ។

ដំណោះស្រាយ

ក.ស្រាយបញ្ជាក់ថាសមីការយ៉ាងហោចណាស់មានឫសពិតមួយចន្លោះ $[0,\frac{\pi}{4}]$

គេមានសមីការ $x\tan x=\cos x$

តាងអនុគមន៍ $f(x)=x\tan x-\cos x$

មានដែនកំណត់ $D_f=\mathbb{R}-\{\frac{\pi}{2}+k\pi\ ,\ k\in\mathbb{Z}\}$ ។

អនុគមន៍ f ជាប់លើចន្លោះ $[\,0\,,\frac{\pi}{4}\,]$ ។

គេមាន $f(0)=-1$ និង $f(\frac{\pi}{4})=\frac{\pi}{4}-\frac{\sqrt{2}}{2}>0$

ដោយ $f(0)\times f(\frac{\pi}{4})<-(\frac{\pi}{4}-\frac{\sqrt{2}}{2})<0$ នោះតាមទ្រឹស្តីបទតម្លៃ

កណ្តាលយ៉ាងហោចណាស់មានចំនួនពិត c មួយនៃ $[\,0\,,\frac{\pi}{4}\,]$

ដែល $f(c)=0$ ។ ដូចនេះសមីការ $x\tan x=\cos x$ យ៉ាងហោចណាស់

មានឫសពិតមួយចន្លោះ $[\,0\,,\frac{\pi}{4}\,]$ ។

ខ.ស្រាយបញ្ជាក់ថាសមីការ $(x^n-1)\cos x+\sqrt{2}\sin x-1=0$

យ៉ាងហោចណាស់មានឫសពិតមួយចន្លោះ $(\,0\,,1\,)$ ។

តាងអនុគមន៍ $f(x)=(x^n-1)\cos x+\sqrt{2}\sin x-1$

គេមាន $f(0)=-2$ និង $f(1)=\sqrt{2}\sin 1-1>\sqrt{2}\sin\frac{\pi}{4}-1=0$

ដោយ $f(0)\times f(1)<0$ នោះតាមទ្រឹស្តីបទតម្លៃកណ្តាលយ៉ាងហោចណាស់

មានចំនួនពិត c មួយនៃ $[\,0\,,1\,]$ ដែល $f(c)=0$ ។

ដូចនេះសមីការ $(x^n-1)\cos x+\sqrt{2}\sin x-1=0$ យ៉ាងហោចណាស់មានឫស

ពិតមួយចន្លោះ$(0,1)$ ។

ជំពូកទី០៤

វិធីសាស្ត្រគណនាលីមីតនៃអនុគមន៍មួយចំនួន

លំហាត់ទី០១

គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to2}\left(x^3+x-5\right)$ ខ. $\lim_{x\to3}\left(2x^2-5x+1\right)$ គ. $\lim_{x\to-1}\left(x^4+6x^2+1\right)$

ឃ. $\lim_{x\to2}\left(x+\sqrt{x^3+1}\right)$ ង. $\lim_{x\to3}\left(\sqrt{x+3+\sqrt{x+6}}\right)$ ច. $\lim_{x\to3}\left(x^2-\sqrt[3]{x^2-1}\right)$

ឆ. $\lim_{x\to2}\frac{x^4+3x^2-8}{x^2+1}$ ជ. $\lim_{x\to3}\frac{x^2+5x-4}{2x-1}$ ឈ. $\lim_{x\to1}\frac{\sqrt{x^2+x+2}}{3x+1}$

លំហាត់ទី០២

គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to0}\left(\sin x+\cos x\right)$ ខ. $\lim_{x\to\frac{\pi}{3}}\left(\cos x+\sqrt{3}\sin x\right)$ គ. $\lim_{x\to0}\frac{3+5\cos x}{3-\cos x}$

ឃ. $\lim_{x\to\frac{\pi}{6}}\left(\sin x+2\cos^2 x\right)$ ង. $\lim_{x\to\frac{\pi}{2}}\frac{2\sin x-\cos x}{1+\sin x}$ ច. $\lim_{x\to\frac{\pi}{3}}\frac{1+4\sin^2 x}{1+2\cos x}$

ឆ. $\lim_{x\to\frac{\pi}{3}}\frac{2\cos^2 x+3\cos x+1}{\cos x+\sqrt{3}\sin x}$ ជ. $\lim_{x\to\frac{\pi}{4}}\frac{3+\sqrt{2}\sin x}{3-\sqrt{2}\cos x}$ ឈ. $\lim_{x\to\frac{\pi}{3}}\frac{1+\sqrt{3}\tan x}{1+4\sin^2 x}$

លំហាត់ទី០៣

គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to1}\frac{x-1}{x^2-1}$ ខ. $\lim_{x\to3}\frac{x^2-4x+3}{x-3}$ គ. $\lim_{x\to1}\frac{x^2+x-2}{x^2-3x+2}$

ឃ. $\lim_{x\to2}\frac{x^3-8}{x^3-2x^2+2x-4}$ ង. $\lim_{x\to1}\frac{(x-1)^2}{x^3-x^2-x+1}$ ច. $\lim_{x\to3}\frac{x^3-27}{x^3-3x^2-3x+9}$

ឆ. $\lim_{x\to-1}\frac{x^4+x^3-x^2+1}{x^3+1}$ ជ. $\lim_{x\to1}\frac{x^3+x-2}{x^3-x^2+x-1}$ ញ. $\lim_{x\to2}\frac{x^4-16}{x^3-2x^2+4x-8}$

លំហាត់ទី០៤

គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to1}\frac{x^3-1}{x^2+x-2}$ ខ. $\lim_{x\to3}\frac{x^3-3x^2+45x-135}{x^3-27}$

គ. $\lim_{x\to2}\frac{x^3-8}{x^2-4}$ ឃ. $\lim_{x\to-1}\frac{x^4+x^3+4x+4}{x^3+1}$

ង. $\lim_{x\to2}\frac{x^4-2x^3+x^2-4}{x^3-2x^2-x+2}$ ច. $\lim_{x\to3}\frac{x^2-9}{x^2-3x}$

ឆ. $\lim_{x\to1}\frac{x^3+x-2}{x^2-1}$ ជ. $\lim_{x\to2}\frac{x^2-6x+8}{x^2-3x+2}$

ឈ. $\lim_{x\to0}\frac{(1+x)^4-4x-1}{x^4+x^2}$ ញ. $\lim_{x\to0}\frac{(1+x)(1+2x)(1+3x)-1}{x}$

លំហាត់ទី០៥

គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to4}\frac{x^3-64}{x^2-16}$ ខ. $\lim_{x\to1}\frac{x^3-6x^2+9x-4}{x^3-x^2-x+1}$

គ. $\lim_{x\to2}\frac{5x^2-8x-4}{x^3-8}$ ឃ. $\lim_{x\to3}\frac{x^2-9}{x^2-3x}$

ង. $\lim_{x\to 1}\frac{x^3+x-2}{x^2-1}$ ច. $\lim_{x\to 2}\frac{x^2-6x+8}{x^2-3x+2}$

ឆ. $\lim_{x\to 0}\frac{(1+x)^4-4x-1}{x^4+x^2}$ ជ. $\lim_{x\to 0}\frac{(1+x)(1+2x)(1+3x)-1}{x}$

ឈ. $\lim_{x\to 4}\frac{x^3-64}{x^2-16}$ ញ. $\lim_{x\to 2}\frac{x^3-8+4(x-2)}{x^2-4}$

លំហាត់ទី០៦

គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to 3}\frac{x^3-3x^2+x-3}{2x^2-7x+3}$ ខ. $\lim_{x\to 1}\frac{3x^4-4x^3+1}{(x-1)^2}$

គ. $\lim_{x\to 1}\frac{x^4-4x+3}{x^3-x^2-x+1}$ ឃ. $\lim_{x\to 0}\frac{(1+ax)^n-1}{x}$

ង. $\lim_{x\to 0}\frac{(1+x)^3-(3x+1)}{x^2}$ ច. $\lim_{x\to 0}\frac{1-(1+x)(1+2x)(1+3x)}{x}$

ឆ. $\lim_{x\to 1}\frac{x^n-1}{x-1}$ ដែល $n\in\mathbb{N}$ ជ. $\lim_{x\to 1}\left(\frac{1}{1-x}-\frac{3}{1-x^3}\right)$

ឈ. $\lim_{x\to 2}\frac{x^3-3x^2+4}{x^3-4x^2+4x}$ ញ. $\lim_{x\to 1}\frac{x^3-x^2+x-1}{x^3-1}$

លំហាត់ទី០៧

គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to -1}\frac{x^2-1}{x+1}$ ខ. $\lim_{x\to 2}\frac{x^2-4}{x-2}$

គ. $\lim_{x\to 3}\frac{x^3-27}{x-3}$ ឃ. $\lim_{x\to -4}\frac{x^3+64}{x+4}$

ង. $\lim_{x\to 2}\left(\frac{1}{2-x}-\frac{12}{8-x^3}\right)$ ច. $\lim_{x\to 2}\left[\frac{x(x+1)}{x-2}-\frac{6x^2}{x^2-4}\right]$

ឆ. $\lim_{x\to1}\frac{x^3+x-2}{x^2-1}$

ជ. $\lim_{x\to2}\frac{x^5-32}{x^4-16}$

ឈ. $\lim_{x\to1}\frac{x^5+x^3-1}{x^4-1}$

ញ. $\lim_{x\to2}\frac{x^3-8}{x^4-2x^3-x^2+4}$

លំហាត់ទី០៨

គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to1}\frac{x^4-2x^2+1}{x^3-3x+2}$

ខ. $\lim_{x\to3}\frac{x^3-3x^2+7x-21}{x^3-3x^2-x+3}$

គ. $\lim_{x\to2}\frac{x^6-64}{x^4-2x^3+8x-16}$

ឃ. $\lim_{x\to1}\frac{2x^2-5x+3}{x^2-3x+2}$

ង. $\lim_{x\to2}\frac{x^3-3x-2}{x^2-5x+6}$

ច. $\lim_{x\to1}\frac{x^3-3x+2}{2x^3-3x+1}$

ឆ. $\lim_{x\to1}\frac{x^4-4x+3}{(x-1)^2}$

ជ. $\lim_{x\to2}\frac{x^3-2x^2+2x-4}{x^2-6x+8}$

ឈ. $\lim_{x\to\frac{\pi}{6}}\frac{2\sin^2x-3\sin x+1}{4\sin^2x-1}$

ញ. $\lim_{x\to\frac{\pi}{6}}\frac{8\sin^3x-1}{2\sin^2x-3\sin x+1}$

លំហាត់ទី០៩

គណនាលីមីតខាងក្រោម៖

ក. $\lim_{x\to1}\left(\frac{2}{1-x^2}-\frac{3}{1-x^3}\right)$

ខ. $\lim_{x\to0}\frac{(1+x)^4-4x-1}{x^3+x^2}$

គ. $\lim_{x\to2}\frac{x+x^2+x^3-12}{x-2}$

ឃ. $\lim_{x\to1}\frac{x+2x^2+3x^3-6}{x-1}$

ង. $\lim_{x\to1}\frac{x^3-3x^2+3x-1}{(x^3-x)^3}$

ច. $\lim_{x\to-1}\frac{x^2+3x+2}{x^2-2x-3}$

ឆ. $\lim_{x\to\frac{1}{2}}\frac{2x^2-x}{2x^2-3x+1}$

ជ. $\lim_{x\to a}\frac{x^n-a^n}{x-a}$ ($n\in\mathbb{N}$) ។

ឈ. $\lim_{x\to1}\frac{x+x^2+x^3-3}{x-1}$

ញ. $\lim_{x\to1}\frac{x+x^2+x^3+\ldots+x^n-n}{x-1}$ ។

លំហាត់ទី១០

គណនាលីមីតខាងក្រោម៖

ក. $\lim_{x\to\frac{\pi}{3}}\frac{\tan^2x-(1+\sqrt{3})\tan x+\sqrt{3}}{\sin x-\sqrt{3}\cos x}$

ខ. $\lim_{x\to\frac{\pi}{4}}\frac{\tan^2x-3\tan x+2}{\sin x-\cos x}$

គ. $\lim_{x\to\frac{\pi}{4}}\frac{\cos 2x}{\cos^3x-\sin^3x}$

ឃ. $\lim_{x\to\frac{\pi}{3}}\frac{4\cos^2x-1}{\sin x-\sin 2x}$

ង. $\lim_{x\to\frac{\pi}{4}}\frac{1-\tan^3x}{\cos 2x}$

ច. $\lim_{x\to\frac{\pi}{6}}\frac{\cos 3x}{\cos x-\sin 2x}$

ឆ. $\lim_{x\to\frac{\pi}{4}}\frac{\sin x-\cos x}{1-\tan^3x}$

ជ. $\lim_{x\to0}\frac{1-\cos 2x}{\sin^2x+\sin^3x}$

ឈ. $\lim_{x\to\frac{\pi}{3}}\frac{3-4\sin^2x}{2\cos x-1}$

ញ. $\lim_{x\to0}\frac{2x-x^2-\sin^2x}{\cos x+x-1}$

លំហាត់ទី១១

គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to\frac{\pi}{6}}\frac{\cos x-\sin 2x}{4\cos^2x-3}$

ខ. $\lim_{x\to0}\frac{\cos x-\sqrt{x^2+1}}{x^2+\sin^2x}$

គ. $\lim_{x\to\frac{\pi}{4}}\frac{\tan^4x+\cot^4x-2}{1-\sin 2x}$

ឃ. $\lim_{x\to\frac{\pi}{4}}\frac{\sin x-\cos x}{1-\sqrt[3]{\tan x}}$

ង. $\lim_{x\to\frac{\pi}{6}}\frac{1-8\sin^3x}{4\cos^2x-3}$

ច. $\lim_{x\to0}\frac{x^4-\sin^4x}{\sqrt{x^2+1}-\cos x}$

ឆ. $\lim_{x\to\frac{\pi}{4}}\frac{\cos^3 x-\sin^3 x}{1-\tan^2 x}$

ជ. $\lim_{x\to\frac{\pi}{3}}\frac{3-4\sin^2 x}{2\cos x-1}$

ឈ. $\lim_{x\to\frac{\pi}{6}}\frac{4\cos^2 x-3}{1-2\sin x}$

ញ. $\lim_{x\to\frac{\pi}{2}}\frac{2-\sin x-\sin^2 x}{1-\sin x}$

លំហាត់ទី១២

គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to 0}\frac{2\sin x-\sin 2x}{\sin x(1-\cos^3 x)}$

ខ. $\lim_{x\to\frac{\pi}{6}}\frac{2\sin^2 x-3\sin x+1}{2\sin x-1}$

គ. $\lim_{x\to\frac{\pi}{4}}\frac{1-\tan^3 x}{\cos x-\sin x}$

